**Regional ToT, Kathmandu, Nepal, 23-26 February 2018**
**ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់**
**ទីក្រុង កាត្មាន់ឌុ ប្រទេសណេប៉ាល់ ថ្ងៃទី២៣-២៦ ខែកុម្ភៈ ឆ្នាំ២០១៨**

## Handout 1.4 Good practices: Ending child labour in domestic work and protecting young domestic workers *(Source: IDWF/ILO Handbook on child labour in domestic work)*

## ឯកសារ ១.៤ ការអនុវត្តល្អ៖ ការបញ្ចប់ពលកម្មកុមារក្នុងការងារតាមផ្ទះ និងការការពារអ្នកធ្វើការតាមផ្ទះវ័យក្មេង *(ប្រភព៖ សៀវភៅ IDWF/ILO ស្តីពីពលកម្មកុមារក្នុងការងារតាមផ្ទះ)*

នៅជុំវិញពិភពលោកនេះ រដ្ឋាភិបាល សហជីព អង្គការអ្នកធ្វើការងារតាមផ្ទះ និងអង្គកមិនមែនរដ្ឋាភិបាលនានា បានចាត់វិធានការសំខាន់ៗដើម្បីបញ្ចប់ពលកម្មកុមារធ្វើការតាមផ្ទះដែលមានលក្ខណៈកេងប្រវ័ញ្ចនិងមានការរំលោភបំពាន និងដើម្បីការពារកុមារធ្វើការងារតាមផ្ទះដែលអាយុអាចធ្វើការស្របតាមការកំណត់របស់ច្បាប់។ ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួន៖

- ក្នុងខែមិនា ឆ្នាំ២០១៣ **ប្រទេសអាហ្សង់ទីន** បានអនុម័តច្បាប់ស្តីពីអ្នកធ្វើការតាមផ្ទះថ្មីមួយដែលមានកំណត់អាយុអប្បបរមា ១៦ឆ្នាំ សម្រាប់ការងារតាមផ្ទះ, ដាក់កំណត់ទៅលើចំនួនម៉ោងធ្វើការសម្រាប់អ្នកធ្វើការចន្លោះអាយុ១៦ដល់១៨ឆ្នាំ ឲ្យធ្វើការតែចំនួន ៣៦ ម៉ោងក្នុង១សប្តាហ៍ ព្រមទាំងហាមឃាត់អ្នកធ្វើការតាមផ្ទះដែលមានអាយុក្រោម១៨ មិនឲ្យរស់នៅក្នុងផ្ទះរបស់និយោជកទេ។
- ក្នុង**ប្រទេសស្រីលង្កា** អាជ្ញាធរជាតិការពារកុមារ មានអំណាចក្នុងការចូលទៅឆែកនៅក្នុងទីតាំងណា ដែលខ្លួនមានហេតុផលក្នុងការជឿថាកំពុងកើតមានអំពើរំលោភបំពានលើកុមារ ដោយរួមទាំងផ្ទះឯកជនផង។
- ក្នុង**ប្រទេសតង់ហ្សានៀ** សហជីពឈ្មោះចូដាវូ បានបង្កើតគណៈកម្មការពលកម្មកុមារនៅក្នុងភូមិ ដើម្បីជួយកំណត់រកករណីពលកម្មកេងប្រវ័ញ្ច, សម្របសម្រួលក្នុងការដកកុមារចេញពីស្ថានភាពកេងប្រវ័ញ្ច និងផ្តួចផ្តើមវិធានការផ្លូវច្បាប់ទៅលើនិយោជក នៅពេលដែលចាំបាច់។
- ក្នុង**ប្រទេសកម្ពុជា** គណៈកម្មការអន្តរសហជីពដើម្បីពលកម្មកុមារ មានគោលនយោបាយគ្របដណ្តប់ទូទាំងសហជីពស្តីពីពលកម្មកុមារធ្វើការតាមផ្ទះ ដែលចែងថា គ្មានសមាជិកសហជីពណាមួយ អាចជួលកុមារធ្វើការតាមផ្ទះដែលមានអាយុក្រោម១៥ឆ្នាំបានឡើយ។ គោលនយោបាយនេះ ក៏បានបញ្ជាក់ច្បាស់អំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កុមារធ្វើការងារតាមផ្ទះដែលអាយុលើពីអាយុអប្បបរមា ចំនួន ៦០.០០០ រៀល (បទ$១៥) ដោយមិនរាប់បញ្ចូលអាហារ ការស្នាក់នៅ និងផលប្រយោជន៍ផ្សេងទៀត ដូចជាសម្ភារៈសិក្សា សម្លៀកបំពាក់ ប្រាក់រង្វាន់ ជាដើម។

- ក្នុង**ប្រទេសហ្វីលីពីន** វេទិកាអង្គការវិសាយ៉ាន បានធ្វើការជាមួយអ្នកគ្រប់គ្រងរដ្ឋបាលសាលារៀន ដើម្បីបង្កើតកម្មវិធីសិក្សាពិសេស សម្រាប់កុមារធ្វើការងារតាមផ្ទះដែលអនុញ្ញាតឲ្យពួកគេបានចូលសាលារៀននៅរៀងរាល់ថ្ងៃអាទិត្យ ដែលជាថ្ងៃឈប់សម្រាកទូទៅ និងដើម្បីជាចុងក្រោយទទួលបានសញ្ញាប័ត្រ។

ប្រទេសមួយចំនួន រួមមាន **បង់ក្លាដេស ប្រេស៊ីល ហ្គាណា ឥណ្ឌូណេស៊ី ម៉ិចស៊ិច ម៉ូរ៉ុក ហ្វីលីពី និងតួកគី** បានកាត់បន្ថយអាត្រាពលកម្មកុមារ រួមទាំងកាត់បន្ថយកុមារធ្វើការតាមផ្ទះផង តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារក្រីក្រ ដើម្បីលប់បំបាត់គំនាបហិរញ្ញវត្ថុដែលត្រូវបញ្ជូនកុមារទៅធ្វើការ។

- យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយក្នុង**ប្រទេសកូស្តារីកា ប្រទេសហុងឌុយរ៉ាស និងប្រទេសប៉ាណាម៉ា** បានផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍នៅតាមប៉ុស្តិ៍សំខាន់ៗ ដើម្បីលើកកម្ពស់ការយល់ដឹងនិងទប់ស្កាត់ពលកម្មកុមារធ្វើការតាមផ្ទះ។
- ក្នុង**ប្រទេសតូហ្គូ** អង្គការវ៉ាវអាហ្វ្រិក ( NGO WAO Afrique ) បានបញ្ជូនបុគ្គលិកសង្គមកិច្ចទៅតាមផ្ទះនិមួយៗ ដើម្បីកំណត់រកកុមារធ្វើការតាមផ្ទះ និងផ្តល់ព័ត៌មានស្តីពីសិទ្ធិកុមារ។ អង្គការនេះ អាចដកកុមារជាច្រើនរយនាក់ចេញពីការងារតាមផ្ទះនិងឲ្យពួកគេបានជួបជុំជាមួយគ្រួសារវិញ។
- រដ្ឋាភិបាល**ប្រទេសណាមីប៊ីយ៉ា** បានចាត់តាំងឲ្យមានគណៈកម្មាធិការប្រាក់ឈ្នួលសម្រាប់អ្នកធ្វើការតាមផ្ទះក្នុងឆ្នាំ២០១២ បន្ទាប់ពីមានការគាំទ្រពីដៃគូសង្គមនានា។ គណៈកម្មាធិការដែលមានសមាជិកចំនួន៥រូបនោះ បានបញ្ចូលតំណាងមកពីសហជីព និងសហព័ន្ធនិយោជក។ គណៈកម្មាធិការនេះមានអាណត្តិទូលាយ ក្នុងការផ្តល់អនុសាសន៍ឲ្យមានប្រាក់ឈ្នួលអប្បបរមាថ្មីមួយសម្រាប់អ្នកធ្វើការតាមផ្ទះ, ក្នុងការស៊ើបអង្កេតលក្ខខណ្ឌការងារ និងក្នុងការផ្តល់អនុសាសន៍អំពីការការពារកុមារធ្វើការតាមផ្ទះ ដោយប្រើប្រាស់អនុសញ្ញា ILO ១៨៩ ជាមគ្គុទេសក៏។
- ក្នុង**ទ្វីបអាស៊ី** គម្រោង ILO Promote ផ្តោតទៅលើការលុបបំបាត់ពលកម្មកុមារនៅក្នុងការងារតាមផ្ទះ តាមរយៈការពង្រឹងសមត្ថភាពអង្គការអ្នកធ្វើការងារតាមផ្ទះ ដើម្បីគាំទ្រនិងចងក្រងអ្នកធ្វើការតាមផ្ទះ។ យុទ្ធសាស្ត្រសំខាន់ៗរបស់គម្រោងនេះ គឺ គាំទ្រឲ្យមានការផ្តល់សច្ចាប័នអនុសញ្ញា ILO, ក្នុងប្រទេសឥណ្ឌូណេស៊ី ការលើកកម្ពស់ការអនុម័តច្បាប់ស្តីពីការងារតាមផ្ទះនិងបទប្បញ្ញត្តិថ្នាក់ខេត្តនិងថ្នាក់ស្រុក ដើម្បី លប់បំបាត់ពលកម្មកុមារក្នុងការងារ, លើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយសហជីពនិងអង្គការអ្នកធ្វើការងារតាមផ្ទះនៅកម្រិតតំបន់និងកម្រិតអន្តរជាតិ ព្រមទាំងបង្កើនការរៀនសូត្រនិងសកម្មភាពទូទាំងទ្វីបអាស៊ីស្តីពីការងារល្អប្រសើរសម្រាប់អ្នកធ្វើការងារតាមផ្ទះ។